# មិត្តភក្តិ និង សេចក្តីជំនឿ

ដោយ មេលីសា ហាត រដ្ឋ យូថាហ៍ ស.រ.អា.




ជំរាបសួរ ! ខ្ញុំឈ្មោះ អ៊ីវ៉ាណា ។

ខ្ញុំរស់នៅក្នុង បូហ្គូតា កូឡុំប៊ី ហើយខ្ញុំបានឈរយ៉ាងរឹងមាំ ដោយចែកចាយដំណឹងល្អជាមួយ មិត្តភក្តិ និង គ្រួសាររបស់ខ្ញុំ ។



ខ្ញុំទៅរៀននៅសាលាកាតូលិក ។ ជំនឿរបស់ខ្ញុំមួយចំនួនផ្សេងពីអស់អ្នកដែលនៅក្នុងថ្នាក់ និង គ្រូបង្រៀនរបស់ខ្ញុំ ប៉ុន្តែពួកគេគោរពខ្ញុំ ហើយខ្ញុំគោរពពួកគេ ។ ពួកគេចង់ដឹងពីសាសនារបស់ខ្ញុំ ហើយខ្ញុំត្រូវតែចែកចាយវាជាមួយពួកគេ ! ឥឡូវនេះខ្ញុំនៅជាមួយមិត្តភក្តិរបស់ខ្ញុំគឺ លូីសា ។

គ្រូម្នាក់បានសួរខ្ញុំ ប្រសិនបើយើងមានជំនឿដូចគ្នាទៅនឹងពួកកាតូលិកដែរឬទេ ។ ខ្ញុំប្រាប់គាត់ថា យើងជឿលើព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំក៏និយាយអំពីព្រះគម្ពីរមរមន ព្រះគម្ពីរប៊ីប និង គោលលទ្ធិ និង សេចក្តីសញ្ញា ។

ប៉ារបស់ខ្ញុំពុំមែនជាសមាជិកនៃសាសនាចក្រឡើយ ប៉ុន្តែគាត់បានមកចូលរួមកម្មវិធីផ្សេងៗជាញឹកញាប់ ។ ខ្ញុំឱដងគាត់ថា គាត់គឺជា « ពួកកាតាលិកមរមន » ។



យើងបានទៅទស្សនាទីក្រុង សលត៍ លេក ពេលសន្និសីទទូទៅ ហើយបានស្តាប់ប្រធាន ម៉នសុន មានប្រសាសន៍ ។ ប្រសាសន៍របស់លោកគឺអស្ចារ្យណាស់ ហើយប្រសាសន៍នោះបង្រៀនអំពីដំណឹងល្អ ។





ខ្ញុំបានអញ្ជើញមិត្តភក្តិម្នាក់មកពីសាលាមកចូលរួមបុណ្យជ្រមុជទឹករបស់ខ្ញុំ ហើយនាងបានមក ! ខ្ញុំរីករាយណាស់ដែលបានចែកចាយបទពិសោធន៍ជាមួយនាង ។







ព្រះវិហារបរិសុទ្ធ បូហ្គូតា កូឡុំប៊ី ស្រស់ស្អាតណាស់ ។ ខ្ញុំចង់ចូលទៅក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃណាមួយ ដូច្នោះខ្ញុំអាចរៀនបន្ថែមទៀតពីដំណឹងល្អ ។ មិត្តភក្តិរបស់ខ្ញុំឈ្មោះ ឡូរ៉ាបានមកជាមួយខ្ញុំ ។



## យោបល់របស់អ៊ីវ៉ាណា ដើម្បីឈរយ៉ាងរឹងមាំ

ញញឹម ហើយចែកចាយរឿងនានាពីសាសនាចក្រ និង ព្រះគម្ពីរជាមួយអ្នកដទៃ ។

ចូលរួមការប្រជុំសាសនាចក្ររៀងរាល់ថ្ងៃអាទិត្យ ។

ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។

ព្យាយាមអានព្រះគម្ពីររាល់ថ្ងៃ ។